ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៨៣០ MIH / 2016

# សេចក្តីណែនាំ

ក្នុងគោលបំណងរួមចំណែកជួយរំលែកការលំបាកចំពោះមុខរបស់ប្រជាពលរដ្ឋ ដែលទទួលរងគ្រោះដោយបាតុភូតធម្មជាតិរាំងស្ងួត និងរលកកម្តៅខ្លាំង ហើយកំពុងប្រឈមនឹងកង្វះទឹកស្អាតសម្រាប់បរិភោគ និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងយោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**

ក្រសួងឧស្សាហកម្ម និងសិប្បកម្មដាក់ចេញនូវសេចក្តីណែនាំអនុវត្តវិធានការមួយចំនួន ដើម្បីចូលរួមចំណែកដល់យុទ្ធនាការផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋនៅតាមតំបន់ដែលមានការខ្វះខាតទឹក ដូចមានខ្លឹមសារខាងក្រោម ៖

១- ចេញបញ្ជាឲ្យថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអង្គភាព ទីប្រឹក្សា ចាប់ពីថ្នាក់អគ្គនាយករងឡើងទៅ ត្រូវចុះតាមមូលដ្ឋានរាជធានី ខេត្ត ក្នុងនាមជាសមាជិកក្រុមការងារថ្នាក់ជាតិ ដើម្បីសហការជាមួយអាជ្ញាធរខេត្ត និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត កៀរគរជំនួយឧបត្ថម្ភ គាំទ្រពី ៖

- ក- ប្រតិបត្តិករផលិតទឹកស្អាត ដោយស្នើសុំផ្តល់ជាអំណោយទឹកស្អាត (នឹងអាចស្នើសុំជួយបន្ថែមនូវរថយន្តដឹកទឹក គឺកាន់តែល្អប្រសើរ) សម្រាប់ចែកជូនប្រជាពលរដ្ឋប្រើប្រាស់
- ខ- អាជីវករផលិតទឹកបរិសុទ្ធ ដើម្បីជួយជាអំណោយទឹកបរិសុទ្ធដប (ឬទឹកសុទ្ធជាប៊ីដុង)
- គ- ម្ចាស់សហគ្រាស អាជីវករគ្រប់ប្រភេទ ដែលអាចជួយជាថវិកាដើម្បីទិញទឹកបរិសុទ្ធ ឬទឹកស្អាត ឬជួលរថយន្ត ដើម្បីដឹកទឹកអំណោយឧបត្ថម្ភយកទៅចែកជូនប្រជាពលរដ្ឋ។

២- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវធ្វើបញ្ជីឈ្មោះបណ្តាក្រុមហ៊ុនផលិតទឹកស្អាត ឬផលិតទឹកបរិសុទ្ធ រួមមាន៖ ឈ្មោះអ្នកទទួលខុសត្រូវ, លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង, ទីតាំងឈរជើងនៅតាមមូលដ្ឋាន ហើយនិងទទួលកត់ត្រាឱ្យបានច្បាស់លាស់នូវការជួយឧបត្ថម្ភជាថវិកា ជាទឹកស្អាត ឬទឹកបរិសុទ្ធ ឬជាការជួយដោះស្រាយមធ្យោបាយដឹកទឹកសម្រាប់យកទៅផ្តល់ជូនប្រជាពលរដ្ឋ។ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវដើរតួនាទីជាចំណុចប្រសព្វក្នុងកិច្ចសម្របសម្រួលទំនាក់ទំនង រវាងប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានរាជធានី ខេត្ត អាជ្ញាធរខេត្ត ឬក្រុង ស្រុក ជាមួយនិងប្រតិបត្តិករផលិតទឹកស្អាត និងអាជីវករផលិតទឹកបរិសុទ្ធ ដោយដើរតួជាតំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការស្នើសុំ និងទទួលជំនួយទាំងនោះ។

៣- ចេញបញ្ជាឲ្យគ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត និងរដ្ឋាករទឹកសាធារណៈ រួមចំណែកក្នុងការផ្តល់ទឹកស្អាតតាមចំនួនដែលអាចធ្វើទៅបាន ដោយមិនគិតថ្លៃ សម្រាប់ផ្តល់លទ្ធភាពជូនអាជ្ញាធររាជធានី ខេត្ត ប្រើប្រាស់ក្នុងយុទ្ធនាការនេះ។ ពិនិត្យលទ្ធភាពដោះស្រាយរថយន្តដឹកទឹក ឬប្រើប្រាស់រថយន្តពន្លត់អគ្គីភ័យ ដើម្បីសម្រួលដល់ការដឹកទឹកទៅចែកជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានបានឆាប់រហ័ស ទាន់ពេលវេលា។

៤- ឯកភាពជាគោលការណ៍ឲ្យរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទិញធុងស៊ីទែនដាក់ទឹកចំណុះ៤.០០០លីត្រ ឬ ៥.០០០លីត្រ កែច្នៃដាក់លើរថយន្តដឹកជញ្ជូន ដើម្បីប្រើប្រាស់ជាមធ្យោបាយដឹកជញ្ជូនទឹកស្អាតក្នុងយុទ្ធនាការនេះ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៤៤
អ៊ីម៉ែល: mih.smcabinet@gmail.com

៥- ដោយឡែក មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកែប ត្រូវបញ្ចេញរថយន្តជំនួយពីប្រទេសជប៉ុន ផលិតទឹកស្អាតសម្រាប់ចែកជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានខេត្ត ដោយលើកសំណើស្នើសុំថវិកាទិញប្រេងឥន្ទនៈពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត តាមគោលការណ៍ណែនាំ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ថ្នាក់ដឹកនាំក្រសួង គ្រប់អង្គភាពក្រោមឱវាទក្រសួងទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី ២3 ខែមេសា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u> ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com